**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# លិខិតជូនពរ

**សូមគោរពជូន**
**ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

ក្នុងឱកាសចម្រើនជន្មាយុរបស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ នេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវអំណរសាទរយ៉ាងក្លៀវក្លាបំផុត និងសូមគោរពជូនពរ **ឯកឧត្តម** សូមសម្របកបដោយសុខភាពល្អបរិបូរណ៍ កម្លាំងពលំមាំមួន បញ្ញាញាណវាងវៃ និងជន្មាយុយឺនយូរ។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវគារវកិច្ចដោយស្មោះអស់ពីដួងចិត្តចំពោះសកម្មភាពដ៏ឧត្តុង្គឧត្តមរបស់ **ឯកឧត្តម** ក្នុងបេសកកម្មបម្រើជាតិមាតុភូមិ ដែលបាននិងកំពុងដឹកនាំក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ទទួលបាននូវភាពជោគជ័យយ៉ាងត្រចះត្រចង់ និងភាពល្បីល្បាញនៅលើឆាកអន្តរជាតិ ក្រោមមគ្គុទ្ទេសក៍ភាពដឹកនាំប្រទេសប្រកបដោយគតិបណ្ឌិតដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។**

ជាថ្មីម្តងទៀត ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមគោរពជូនពរ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងលោកជំទាវ ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី** សម្របកបនឹងព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា៕

ថ្ងៃសុក្រ ៩កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ហ៊ុន សុខា